# កិច្ចការបញ្ចប់មេរៀនទី៤ ការសម្អាតថ្នាក់រៀន

**អំណាន:** ចូរអានអត្ថបទខាងក្រោម រួចឆ្លើយនឹងសំណួរ ។

ការសម្អាតថ្នាក់រៀន ជាភារកិច្ចរបស់យើងទាំងអស់គ្នា។

សិស្សថ្នាក់ខ្ញុំ ប្តូរវេនគ្នាសម្អាតបន្ទប់រៀនរៀងរាល់ថ្ងៃ ។ ព្រឹកនេះ ដល់វេនក្រុមខ្ញុំសម្អាតបន្ទប់រៀន ។ មិត្តភក្តិដែលជាសមាជិកក្រុមទាំងអស់នាំគ្នាទៅសាលារៀនមុនម៉ោងសិក្សាដោយយកអំបោស កន្ទប និង ធុងទឹកទៅជាមួយផង ។ ពួកយើងនាំគ្នាបោសបន្ទប់រៀន ជូត កៅអី ទ្វារ និងបង្អួច ។ អ្នកខ្លះ ប្រមូលសំរាម កម្ទេចកម្ទី កើបធូលីយកទៅចោលក្នុងធុងសំរាម ។

ថ្នាក់រៀនខ្ញុំស្អាតជានិច្ច ដោយសិស្សក្នុងថ្នាក់ចូលរួមសម្អាតទាំងអស់គ្នា ។ គ្រូតែងសរសើរពួកយើង គ្រប់ៗគ្នា ។

" អនាម័យនាំមកនូវសុខភាព "

គូសសញ្ញា ✓ ក្នុងប្រអប់ ☐ ចម្លើយមួយដែលត្រឹមត្រូវ ។

១. តើការសម្អាតថ្នាក់រៀន ជាភារកិច្ចរបស់អ្នកណា ?

☐ ក. យើងទាំងអស់គ្នា ☐ ខ. នាយកសាលា

☐ គ. អាណាព្យាបាលសិស្ស ☐ ឃ. គ្រូបង្រៀន

២. តើក្នុងការសម្អាតថ្នាក់រៀន គេបែងចែកដូចម្តេច ?

☐ ក. ម្នាក់ត្រូវសម្អាតពេញមួយឆ្នាំ ☐ ខ. អ្នករៀនខ្សោយត្រូវសម្អាតថ្នាក់

☐ គ. ប្តូរវេនគ្នារៀងរាល់ថ្ងៃ ☐ ឃ. អ្នករៀនពូកែមានសិទ្ធិបញ្ជា

៣. តើសមាជិកក្រុមដែលត្រូវវេនសម្អាតថ្នាក់ត្រូវធ្វើដូចម្តេច ?

☐ ក. ទៅយឺតម៉ោងបន្តិច ☐ ខ. ទៅមុនម៉ោងសិក្សា

☐ គ. គេចមិនជួយក្រុម ☐ ឃ. ទៅតាមម៉ោងដូចសព្វមួយដង

៤. តើល្បះមួយណាទាក់ទងនឹងខ្លឹមសារអត្ថបទខាងលើ ?

☐ ក. ថ្ងៃនេះយើងត្រូវសម្អាតផ្ទះ ☐ ខ. ថ្ងៃនេះយើងត្រូវទៅស្រែ

☐ គ. ថ្ងៃនេះយើងត្រូវវេនសម្អាតបន្ទប់រៀន ☐ ឃ. ថ្ងៃនេះយើងត្រូវទៅប្រឡង

៥. ចូររៀបព្រឹត្តការណ៍តាមលំដាប់អត្ថបទឡើងវិញ ដោយបង់លេខក្នុងប្រអប់ឱ្យបានត្រឹមត្រូវ ។

☐ អ្នកខ្លះប្រមូលសំរាម កម្ទេចកម្ទី កើបធូលីយកទៅចោលក្នុងធុងសំរាម ។

☐ គ្រូបានសរសើរ ពួកយើងគ្រប់ៗគ្នា ។

☐ ពួកយើងនាំគ្នាបោសបន្ទប់រៀន ជូតតុ កៅអី ទ្វារ និងបង្អួច ។

☐ មិត្តភក្តិដែលជាសមាជិកក្រុមទាំងអស់នាំគ្នាទៅសាលារៀនមុនម៉ោងសិក្សា ។

LIVEWORKSHEETS

## សំណេរ

១. ចូរពន្យល់ខាងក្រោមឱ្យបានត្រឹមត្រូវ ។

- ភារកិច្ច(    ) ...........................................................................................។
- សមាជិក(   )...........................................................................................។
- កន្ទប(   ) ...........................................................................................។

២. ចូររកពាក្យបដិសព្ទនឹងពាក្យ " ពង្រាយ " ។

- ពង្រាយ    ≠    ..................................................។

៣. ចូររកពាក្យវេវចនសព្ទនឹងពាក្យ " មិត្តភក្តិ " ។

- មិត្តភក្តិ ...........................................................................................។

៤. ចូរជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញល្បះតាមរូបភាពខាងក្រោមឱ្យបានត្រឹមត្រូវ ។

| | | | |
|---|---|---|---|
| ជានិច្ច | បន្ទប់រៀន | សម្អាត | ចូលរួម |

ក. ព្រឹកនេះ ដល់វេនក្រុមខ្ញុំ...................បន្ទប់រៀន។

ខ.ពួកយើងនាំគ្នាបោសសម្អាត.................ជូតតុ  កៅអី ទ្វារ  និងបង្អួច ។

គ. ថ្នាក់រៀនខ្ញុំស្អាត................ដោយសិស្សក្នុងថ្នាក់...................សម្អាតទាំងអស់គ្នា ។

៥. ចូរតែងល្បះតាមរូបភាពខាងក្រោមឱ្យត្រឹមត្រូវ ។



ក/........................................................

........................................................

........................................................ ។



ខ/........................................................

........................................................

........................................................ ។

LIVEWORKSHEETS